# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាព្រះអម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ
# បាត់ដំបង ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៩
# ព្រះនាងម៉ារីណែនាំឲ្យយើងចូលនៅក្នុងបេះដូងរបស់ព្រះយេស៊ូ

**អត្ថបទទី១៖ វិវរណៈ ១១,១៩ក;១២,១-៦ក.១០ក**

នាងសម្រាលបានបុត្រមួយដែលត្រូវកាន់*ដំបងដែក ដឹកនាំជាតិសាសន៍ទាំងអស់។* ក៏ប៉ុន្តែព្រះជាម្ចាស់បានឆក់យកបុត្រនោះឡើងទៅជាមួយព្រះអង្គ គឺនៅជិតបល្ល័ង្ករបស់ព្រះអង្គ។ វវ ១២,៥

**អត្ថបទទី២៖ កូរិនថូសទី១ ១៥,២០-២៧ក**

បើមនុស្សលោកត្រូវស្លាប់ព្រោះតែមនុស្សម្នាក់ គេក៏នឹងរស់ឡើងវិញដោយសារមនុស្សតែម្នាក់ដែរ។ ១ករ ១៥,២១

**ដំណឹងល្អ៖ លូកា ១,៣៩-៥៦**

នាងពិតជាមានសុភមង្គលមែន ព្រោះនាងបានជឿព្រះបន្ទូល ដែលព្រះអម្ចាស់ប្រាប់នាងមុខជាបានសម្រេចមិនខាន។ លក ១,៤៥

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាឱកាសមួយដើម្បីនឹករលឹកជីវិតរបស់ខ្ញុំនៅក្នុងព្រះសហគមន៍ប្រទេសកម្ពុជា ដែលខ្ញុំបានទទួលយ៉ាងច្រើនជាពិសេសនៅបាត់ដំបង នៅស្វាយស៊ីសុផុន និងចំណោម។ យើងនឹកដល់ព្រះនាងម៉ារី ដែលនៅគ្រប់ទីកន្លែងដើម្បីឲ្យយើងនឹកឃើញជីវិតយ៉ាងពិសេសដែលព្រះនាងម៉ារីបានទទួលពីព្រះជាម្ចាស់។

យើងនឹកឃើញ**ព្រះនាងម៉ារីជាម្តាយ**របស់យើង ជាមាតារបស់ព្រះជាម្ចាស់ មាតារបស់ព្រះសហគមន៍មែន។ ពេលយើងនឹកឃើញម្តាយ ធ្វើឲ្យយើងនឹកឃើញដល់ជីវិតដែលម្តាយប្រគល់ឲ្យកូន យើងនឹកឃើញដល់ព្រះជាម្ចាស់ដែលបានប្រទានជីវិតឲ្យយើងពីដើមរៀងមក។ ណែនាំឲ្យយើងសព្វថ្ងៃ មានជីវិតដ៏ពិសេសពីមួយថ្ងៃទៅមួយថ្ងៃ ព្រះជាម្ចាស់បានបង្កើតយើងជាបុរសជាស្ត្រី ព្រះជាម្ចាស់បានណែនាំឲ្យយើងទទួលដង្ហើមពីព្រះអង្គ។ ពេលយើងទទួលអគ្គសញ្ញាលាបថ្ងាស នៅពេលនោះគឺព្រះវិញ្ញាណដែលយាងមក ជាដង្ហើមរបស់ព្រះជាម្ចាស់ដែលចូលថែមទៀតនៅក្នុងជីវិតរបស់យើង ដើម្បីឲ្យយើងនឹកឃើញពិតមែនម្ចាស់នៃជីវិតរបស់ខ្ញុំគឺព្រះជាម្ចាស់។ ពេលយើងគោរពព្រះនាងម៉ារីដែលជាមាតារបស់យើង មាតារបស់ព្រះយេស៊ូ មាតារបស់ព្រះសហគមន៍ យើងនឹកដល់ជីវិតដ៏ពិសេសដែលយើងទទួលពីព្រះជាម្ចាស់ផ្ទាល់។

យើងនឹកឃើញ**ព្រះនាងម៉ារីជាស្ត្រីម្នាក់** ដែលបានធ្វើដំណើរជាមួយព្រះយេស៊ូ ដែលបានជួបទុក្ខលំបាកនិងការឈឺចាប់នៅក្នុងជីវិត ណែនាំឲ្យយើងយល់ថាជីវិតរបស់យើងក៏ដូចគ្នាដែរ។ យើងជាបុរស យើងជាស្ត្រី យើងឆ្លងកាត់គ្រប់បញ្ហា គ្រប់កាលៈទេសៈនៅក្នុងជីវិត អំណរសប្បាយផង ទុក្ខលំបាកផង សេចក្តីសង្ឃឹមផង។ យើងឃើញទុក្ខលំបាកដែលគ្រួសារនីមួយៗត្រូវតែមាន ប៉ុន្តែយើងដឹងថាយើងមានព្រះនាងម៉ារីដែលជាគំរូមួយយ៉ាងពិសេស ដើម្បីលើកទឹកចិត្តយើងឲ្យយើងធ្វើដំណើរទៅមុខបាន។ នៅពេលព្រះនាងម៉ារីនៅក្បែរឈើឆ្កាង ព្រះនាងម៉ារីបានសម្លឹងមើលព្រះយេស៊ូជាកូនបង្កើតរបស់ព្រះនាងកំពុងសោយទិវង្គត ព្រះនាងម៉ារីឈឺចាប់ណាស់។ ប៉ុន្តែ ព្រះនាងម៉ារីទៅមុខទៀត ព្រះនាងម៉ារីនៅក្បែរព្រះយេស៊ូពេលព្រះអង្គមានព្រះជន្មរស់ឡើងវិញ ព្រះនាងម៉ារីបាននៅពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ដើម្បីណែនាំឲ្យក្រុមគ្រីស្តទូត ណែនាំឲ្យព្រះសហគមន៍ ណែនាំឲ្យយើងទាំងអស់ពោរពេញដោយសេចក្តីសង្ឃឹម។ យើងមានព្រះនាងម៉ារី ដែលជាស្ត្រីធម្មតាម្នាក់ ដែលបានឆ្លងគ្រប់កាលៈទេសៈនៃជីវិត ថ្ងៃនេះព្រះនាងម៉ារីបានច្រៀងលើកតម្កើងព្រះជាម្ចាស់ថា "**ព្រលឹងខ្ញុំសូមលើកតម្កើងព្រះជាម្ចាស់ ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំងព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ**"។ ព្រះនាងម៉ារីមានជីវិតធម្មតា ប៉ុន្តែព្រះនាងម៉ារីពោរពេញដោយជីវិតអស្ចារ្យពិសេសដោយសារភ្ជាប់ជាមួយព្រះជាម្ចាស់។

**ព្រះនាងម៉ារីជាសាវ័ករបស់ព្រះយេស៊ូមុនគេបង្អស់** នៅថ្ងៃដែលព្រះនាងម៉ារីបានឯកភាពជាមួយទេវទូតកាព្រីអែល "**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ**" ពីពេលនោះមកព្រះនាងម៉ារីជាសាវ័ករបស់ព្រះយេស៊ូ។ យើងនឹកឃើញព្រះនាងម៉ារីដែលណែនាំឲ្យព្រះយេស៊ូមានជីវិត នៅពេលព្រះនាងម៉ារីចេញធ្វើដំណើរទៅអេហ្ស៊ីប នៅពេលព្រះនាងម៉ារីចិញ្ចឹមព្រះយេស៊ូ នៅពេលព្រះនាងម៉ារីក្នុងមង្គលការភូមិកាណា ព្រះនាងម៉ារីជាសាវ័ករបស់ព្រះយេស៊ូ។ ព្រះនាងម៉ារី បានណែនាំឲ្យយើងចូលនៅក្នុងក្រុមសាវ័ករបស់ព្រះគ្រីស្តដើម្បីធ្វើដំណើរនៅក្នុងពិភពលោកនេះដោយធ្វើជាសាក្សីរបស់ព្រះយេស៊ូ។

**ព្រះនាងម៉ារីណែនាំឲ្យយើងចូលនៅក្នុងបេះដូងរបស់ព្រះយេស៊ូ** ព្រះនាងម៉ារីបានប្រកាសថា "**ព្រលឹងខ្ញុំសូមលើកតម្កើងព្រះជាម្ចាស់ ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំងព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ**" នេះជាអ្វីដែលយើងបានឃើញផ្ទាល់។ ព្រះជាម្ចាស់ បានលើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ព្រះជាម្ចាស់ដែលសង្គ្រោះទាំងរូបកាយទាំងវិញ្ញាណរបស់ព្រះនាងម៉ារីមុនគេ។ ព្រះយេស៊ូបានលើកព្រះនាងម៉ារីទៅជាមួយព្រះជាម្ចាស់អស់កល្បជានិច្ច គឺព្រះយេស៊ូដែលបានស្វាគមន៍មាតារបស់ព្រះអង្គនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះយេស៊ូបានយកម្តាយឡើងស្ថានបរមសុខ ដើម្បីពោរពេញដោយសុភមង្គលដូចព្រះនាងម៉ារីច្រៀងកោតសរ

សើរ។ ថ្ងៃនេះ ព្រះនាងម៉ារីបានឡើងស្ថានបរមសុខដើម្បីណែនាំឲ្យយើងធ្វើដំណើរលើផែនដីនេះ និងថ្ងៃអនាគតយើងសង្ឃឹមថាយើងបានឡើងស្ថានបរមសុខដែរ។

**ព្រះនាងម៉ារី ណែនាំឲ្យយើងទទួលជីវិតទាំងរូបកាយទាំងវិញ្ញាណអស់កល្បជានិច្ចរួមជាមួយព្រះជាម្ចាស់** ពេលយើងឃើញព្រះនាងម៉ារីចូលនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ យើងដឹងថាយើងមានទីលំនៅយ៉ាងពិសេសនៅព្រះដំណាក់របស់ព្រះជាម្ចាស់ឯស្ថានបរមសុខ។ យើងត្រូវការគិត អំពីជីវិតរបស់យើងសព្វថ្ងៃដើម្បីរៀបចំខ្លួន ព្រោះយើងមិនដឹងថាព្រះជាម្ចាស់មានគម្រោងការអ្វីខ្លះសម្រាប់ជីវិតយើងទេ។ ព្រះនាងម៉ារី ពេលកំពុងរៀបចំអាពាហ៍ពិពាហ៍ជាមួយលោកយ៉ូសែប ពេលនោះទេវទូតកាព្រីអែលមកប្រាប់ដំណឹងថាសូមធ្វើជាមាតារបស់ព្រះយេស៊ូ ព្រះនាងម៉ារីបានប្តូរគម្រោងការភ្លាម។ ទោះបីព្រះនាងម៉ារីមិនយល់ប៉ុន្មានទេ ប៉ុន្តែព្រះនាងម៉ារីបានឯកភាពចូលនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់ ធ្វើជាមាតារបស់ព្រះយេស៊ូ។ ពីមួយថ្ងៃទៅមួយថ្ងៃ ឲ្យយើងយកចិត្តទុកដាក់ទទួលខុសត្រូវ យើងទទួលតួនាទីអ្វីខ្លះនៅក្នុងសង្គម នៅក្នុងគ្រួសារ នៅក្នុងព្រះសហគមន៍ ឲ្យយើងយកចិត្តទុកដាក់ដើម្បីទទួលអ្វីដែលព្រះជាម្ចាស់បានរៀបចំឲ្យយើងដូចព្រះនាងម៉ារី។

ពេលយើងមើលព្រះនាងម៉ារី ណែនាំឲ្យយើងមានសេចក្តីសង្ឃឹម ឲ្យយើងយល់ថា**តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍ សម្រាប់ពិភពលោក និងសម្រាប់ខ្ញុំផ្ទាល់?** ទោះបីយើងជាមនុស្សធម្មតា ប៉ុន្តែយើងជាមនុស្សពិសេស ដោយសារព្រះជាម្ចាស់បានជ្រើសរើសយើងឲ្យធ្វើជាបុត្រធីតារបស់ព្រះអង្គ។

សូមព្រះជាម្ចាស់ប្រទានពរ ដើម្បីឲ្យយើងពោរពេញដោយជីវិតរស់នៅជាសាវ័ក ជាគ្រីស្តទូតរបស់ព្រះជាម្ចាស់ដូចព្រះនាងម៉ារី។ អាម៉ែន៕